# ក្រឹត្យលេខ ១៣ អ.ន.ក្រ

**ស្តីពីអំពីការបំពេញបន្ថែមនៃអនុក្រឹត្យលេខ ១១ អ.ន.ក្រ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៨៣ ស្តីពីបទបញ្ជាផ្ទៃក្នុងរបស់កំពង់ផែសម្រាប់នាវាបរទេសដែលចេញចូលកំពង់ផែ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា**

# ក្រុមប្រឹក្សារដ្ឋ

-បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

-បានឃើញច្បាប់ ស្តីអំពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយក្រឹត្យលេខ០៣ ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២ ។

-បានឃើញអនុក្រឹត្យលេខ ១១ អ.ន.ក្រ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៨៣ ស្តីពីបទបញ្ជាផ្ទៃក្នុងរបស់កំពង់ផែសម្រាប់នាវាបរទេស ដែលចេញចូលកំពង់ផែ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

-បានឃើញក្រឹត្យ-ច្បាប់លេខ ០៧ ក្រ.ច ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា ។

-តាមសំណើ របស់ក្រសួងគមនាគមន៍ដឹកជញ្ជូន និងប្រៃសណីយ៍ ។

**<u>សម្រេច</u>**

*មាត្រាតែមួយ*

**មាត្រា** ១.៣.៦.៨.២៨ នៃអនុក្រឹត្យលេខ១១ អ.ន.ក្រ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៨៣ ស្តីពីបទបញ្ជាផ្ទៃក្នុងរបស់កំពង់ផែសម្រាប់នាវាបរទេសដែលចេញចូលកំពង់ផែ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានកែដូចតទៅ

**មាត្រា ១ ថ្មី** -កំពង់ផែ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលត្រូវកំណត់ជាកំពង់ផែពាណិជ្ជកម្មអន្តរជាតិ គឺកំពង់ផែភ្នំពេញ និងកំពង់ផែកំពង់សោម ។

ក្រៅពីកំពង់ផែទាំងពីរខាងលើ គឺមិនកំណត់ជាកំពង់ផែពាណិជ្ជកម្មអន្តរជាតិ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជាឡើយ ។

នាវាបរទេសទាំងឡាយដែលចូល ឬ ចេញពីកំពង់ផែនសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវអនុវត្តតាមបទបញ្ជាដែលមានចែងក្នុងមាត្រាជាបន្តបន្ទាប់ដូចខាងក្រោម ៖

**មាត្រា ៣ ថ្មី** ពេលធ្វើដំណើរមកកាន់កំពង់ផែ នាវាត្រូវផ្តល់ដំណឹងទៅការិយាល័យនាវាចរ និងកិច្ចការកំពង់ផែតាមរយៈកាំសាបអោយបាន ៧២ ម៉ោងម្តង ៤៨ ម៉ោងម្តង និង ២៤ ម៉ោងម្តង មុននាវាមកដល់ស្ថានីយ៍កណ្តូធារ ឬ ចំណុចពោងសូន្យដើម្បីការិយាល័យនាវាចរ និងកិច្ចការកំពង់ផែចាត់កណ្តូធារអោយនាំផ្លូវ ។

**មាត្រា ៦ ថ្មី** នាវិក និង អ្នកដំណើរទាំងអស់ត្រូវមានវត្តមាននៅពេលធ្វើការត្រួតពិនិត្យ មេបញ្ជាការនាវា ឬ តំណាងមេបញ្ជាការនាវាដែលមានភារកិច្ចប្រចាំថ្ងៃ ត្រូវបានអនុញ្ញាតអោយចូលរួមក្នុងរយៈពេលធ្វើការត្រួតពិនិត្យបែបបទ ។

គណៈកម្មការចម្រុះ ត្រួតពិនិត្យបែបបទនាវាបរទេសទាំងឡាយចាប់ផ្តើមត្រួតពិនិត្យនេះ។ ពេលនាវាចូលដល់ព្រំដែនកម្ពុជា និងពេលនាវាចាកចេញពីកំពង់ផែវិញមាន

១-តំណាងអង្គភាពកំពង់ផែ ប្រធាន

២-តំណាងនគរបាលកំពង់ផែ　　　　　　សមាជិក
៣-តំណាងគយកំពង់ផែ　　　　　　...........
៤-តំណាងចត្តាឡីស័ក　　　　　　...........
៥-តំណាងភូតគាមអនាម័យ　　　　　　...........
៦-អង្គភាពភ្នាក់ងារនាវាចរ　　　　　　...........

**ក-មេបញ្ជាការនាវា ឬ តំណាងមេបញ្ជាការនាវាត្រូវប្រគល់ឯកសារដូចខាងក្រោមនេះទៅអោយគណៈកម្មការត្រួតពិនិត្យ ៖**

| | |
|---|---|
| ១-លិខិតអនុញ្ញាតនៃការចេញដំណើរពីកំពង់ផែចុងក្រោយបំផុត | ១-ច្បាប់ |
| ២-ប្រតិវេទន៍នៃការមកដល់របស់នាវា | ៣- |
| ៣-បញ្ជីរាយនាមនាវិក | ៨-តាមគំរូ |
| ៤-ចក្កីរាយនាមអ្នកដំណើរបើសិនមាន | ៨-តាមគំរូ |
| ៥-លិខិតប្រកាសសុខភាពនៅពេលមកដល់ | ១- |
| ៦-និវេទប័ណ្ណ និងប្លង់រៀបទំនិញ | ៤- |
| ៧-បញ្ជីរូបិយប័ណ្ណ មាស ប្រាក់ | ២- |
| ៨-បញ្ជីសម្ភារប្រើប្រាស់របស់នាវិក | ២-តាមគំរូ |
| ៩-បញ្ជីសម្ភារប្រើប្រាស់របស់អ្នកដំណើរ | ២-តាមគំរូ |
| ១០-បញ្ជីគ្រឿងផ្ទះ គ្រឿងពុល គ្រឿងញៀន | ២- |
| ១១-បញ្ជីសម្ភារដែលត្រូវហាមឃាត់មិនអោយបើនៅកំពង់ផែ | ៤-តាមគំរូ |
| ១២-ប័ណ្ណភូតគាមអនាម័យ និង បសុព្យាបាល | ១- |
| ១៣-បញ្ជីស្បៀងសម្រាប់នាវិក | ២-តាមគំរូ |

ខ-ក្នុងការត្រួតពិនិត្យត្រូវបង្ហាញឯកសារដូចតទៅ ៖

១-វិញ្ញាបនប័ត្រដែលនាវាស្ថាបនា និងវិញ្ញាបនប័ត្រចុះបញ្ជីការ
២-វិញ្ញាបនប័ត្រកម្រិតផ្ទុកទំនិញ
៣-វិញ្ញាបនប័ត្របញ្ជាក់សុវត្ថិភាពឧបករណ៍ប្រើប្រាស់
៤-លិខិតអនុញ្ញាតអោយប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍នៅលើនាវា
៥-ប្រតិវេទន៍វិញ្ញាបនប័ត្រពន្យារពេល
៦-លិខិតបញ្ជាក់របស់ចត្តាឡីស័កចំពោះនាវិកនិងអ្នកដំណើរ
៧-លិខិតបញ្ជាក់បានសម្លាប់សត្វកណ្តុរលើនាវាអស់ហើយ
៨-សៀវភៅនាវិកនិងលិខិតឆ្លងដែនអ្នកដំណើរ
៩-ប័ណ្ណទំនិញឆ្លងដែនមានទំនិញធម្មតារុក្ខជាតិ និងសត្វមានជីវិត ។ នាវាត្រូវអនុញ្ញាតឲ្យចូលផែក្រោយពីគណៈកម្មការបានធ្វើការពិនិត្យរួចហើយ ។

**មាត្រា ៨ ថ្មី** ក្នុងពេលស្នាក់នៅកំពុងផែនាវាត្រូវអនុវត្តតាមបែបបទរបស់អាជ្ញាធរកំពង់ផែ

ក-បទបញ្ជារបស់កំពង់ផែ ស្តីពីសុវត្ថិភាពនាវាចរ សុវត្ថិភាពពលកម្មនឹងអនាម័យ ។

ខ-បទបញ្ជារបស់នគរបាលកំពង់ផែធានាសន្តិសុខសណ្តាប់ធ្នាប់របស់កំពង់ផែ និងតំបន់ក្បែរៗនោះ ។

គ-បទបញ្ញារបស់គយនិងរដ្ឋករ អំពីការងារត្រួតពិនិត្យទំនិញនាំចេញនាំចូលនិងឆ្លងដែន និងយកពន្ធលើទំនិញទាំងនោះ ។

**មាត្រា ២៨ ថ្មី** ជនណាប្រព្រឹត្តបទល្មើសនឹងអនុក្រឹត្យនេះយោលទៅតាមបទល្មើសធ្ងន់ ឬ ស្រាលត្រូវផ្តន្ទាទោសតាមច្បាប់របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា តាមរូបភាពដូចខាងក្រោមនេះ ៖

១-ព្រមាន

២-ពិន័យជាប្រាក់

៣-មិនអនុញ្ញាតអោយចេញពីផែ ក្នុងបណ្តាករណីដូចខាងក្រោម ៖

ក-នាវា នាវិក អ្នកដំណើរប្រព្រឹត្តល្មើសនឹងច្បាប់របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា មិនទាន់បានដោះស្រាយរួច ។

ខ-មានជនល្មើសច្បាប់រត់ពន្ធឡើងលើនាវា មិនទាន់បានចាប់ខ្លួន

គ-ដោយសារមានមូលហេតុផ្សេងៗប៉ះពាល់ដល់សន្តិសុខ ។

៤-បណ្តេញអោយចេញផុតពីទឹកដីកម្ពុជា ។

៥-បញ្ជូនខ្លួនទៅតុលាការនិងរឹបអូសនាវា ឬវត្ថុតាង ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៨៦

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**